**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍
**សភាព្រហ្មទណ្ឌ**
សំណុំរឿងព្រហ្មទណ្ឌ
លេខ៦៨៨/៣០-៧-២០១៣
**សាលដីកា**
លេខ០៦ក្រVIយ
ចុះថ្ងៃទី០៦-០២-២០១៤

**គាចនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៩-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី២៣-០១-២០១៤ដែលមានសមាសភាពដូចតទៅ៖

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជំរះ</u>**

**លោក [redacted] ប្រធាន**
**លោក [redacted] ចៅក្រមប្រឹក្សា**
**លោក [redacted] ចៅក្រមប្រឹក្សា**
**តំណាងមហាអយ្យការ**
**លោក [redacted]**
**ក្រឡាបញ្ជី**
**លោកស្រី [redacted]**

ដើម្បីជំនុំជំរះលើបណ្តឹងសុំស្រួចទោស នៃសំណុំរឿងព្រហ្មទណ្ឌលេខ៦៨៨ចុះថ្ងៃទី៣០-៧-២០១៣របស់សាលាឧទ្ធរណ៍ ៖

- **ទណ្ឌិតឈ្មោះ [redacted] ម៉ាត់សេន ហៅ សាហាន់** ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ<u>ឥស្លាម</u> មុខរបរធ្វើចំការ កើតនៅភូមិស្ទឹង ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅសព្វថ្ងៃ [redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted](រ) ប្រពន្ធឈ្មោះ [redacted]មានកូន២នាក់ ទោសពីមុនគ្មាន។<u>ឃុំខ្លួន។</u>

**<u>ឯដំណើររឿងមានដូចតទៅ៖</u>**

I

តាមពាក្យបណ្ដឹងសុំស្រួបទោសចុះថ្ងៃទី១៧.៥.២០១៣របស់ឈ្មោះ[redacted] ម៉ាត់សេន សុំស្រួបទោសបញ្ចូលគ្នាចំពោះសំណុំរឿងរបស់ខ្លួនចំនួន០២រឿង។

**<u>សំណុំរឿងទី១</u>**

**សំណុំរឿងព្រហ្មទណ្ឌលេខ៦៣៥/០៣.១២.២០០៨របស់សាលាឧទ្ធរណ៍ៈ**

**ឃើញ**សាលក្រមព្រហ្មទណ្ឌលេខ៩២«ឃ»/២៨.៧.២០០៥សាលាដំបូងរាជធានីភ្នំពេញ សំរេចដូចតទៅៈ

១.ផ្ដន្ទាទោសឈ្មោះ[redacted] ជិន ភេទប្រុស កើតនៅប្រទេសវៀតណាម ទីលំនៅផ្ទះ[redacted] ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]) ម្ដាយឈ្មោះ[redacted](រ)ប្រពន្ធឈ្មោះ[redacted]។

.ឈ្មោះ[redacted] ម៉ាត់សេន ភេទប្រុស អាយុ៣៥ឆ្នាំ កើតនៅភូមិស្ទឹង ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅសព្វថ្ងៃភូមិ[redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ[redacted](ស) ម្ដាយឈ្មោះ[redacted](រ) ប្រពន្ធឈ្មោះ[redacted] សៈ មានកូន២នាក់ ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារម្នាក់ៗកំណត់ចំនួន១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) គិតចាប់តាំងពីថ្ងៃឃុំខ្លួន ពីបទជួញដូរមនុស្ស ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៤-០១-២០០៥ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រត់ជួញដូរមនុស្ស និងធ្វើអាជីវកម្មលើមនុស្ស។

២.ផ្ដន្ទាទោសឈ្មោះ[redacted] ធីវ៉ាង ហៅ [redacted]ធីវ៉ា អាយុ៤៥ឆ្នាំ ភេទស្រី កើតនៅសង្កាត់គីឡូលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ មានទីលំនៅសព្វថ្ងៃផ្ទះជួល សង្កាត់[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឡើយ(ស) ម្ដាយឈ្មោះ[redacted] (រ) ប្ដីឈ្មោះ[redacted] មិន មានកូន៣នាក់។

ដាក់ពន្ធនាគារកំណត់ចំនួន១០ឆ្នាំ (ដប់ឆ្នាំ) គិតចាប់តាំងពីថ្ងៃឃុំខ្លួន ពីបទជួញដូរមនុស្ស ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៤-០១-២០០៥ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រត់ ជួញដូរមនុស្ស និងធ្វើអាជីវកម្មលើមនុស្ស។

៣.សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវប្ដឹងទាស់ និង ប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ឃើញ**ពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០១.៨.២០០៥របស់ឈ្មោះ[redacted] ម៉ាត់សេន និង ឈ្មោះ[redacted] ជិន មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៩២«ឃ»/២៨.៧.២០០៥ សាលាដំបូងរាជធានីភ្នំពេញគ្រង់ចំណុចសេចក្ដីសំរេចទាំងមូល។

**ឃើញ**ពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២៧.៩.២០០៥របស់ឈ្មោះ[redacted] ធីវ៉ាង

មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៩២«យ»/២៨.៧.២០០៥របស់សាលាដំបូងរាជធានីភ្នំពេញត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**ឃ្មានឃើញ**សាលដីកាព្រហ្មទណ្ឌលេខ០២«ក្រIIIយ»ចុះថ្ងៃទី០៤.០១.២០១២របស់សាលាឧទ្ធរណ៍ សំរេចសេចក្តីដូចតទៅ៖

១.ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០១.៨.២០០៥របស់ឈ្មោះ [redacted] ម៉ាត់សេន និងឈ្មោះ [redacted] ជិន និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៧.៩.២០០៥របស់ឈ្មោះ [redacted] ធីវ៉ាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២.តំកល់សាលក្រមព្រហ្មទណ្ឌលេខ៩២«យ»/២៨.៧.២០០៥សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល។

៣.បន្តការឃុំខ្លួនលើជនជាប់ចោទតាមច្បាប់។

៤.សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈនៅថ្ងៃទី០៤.០១.២០១២ចំពោះមុខមេធាវីការពារសិទ្ធិជនជាប់ចោទ ជនជាប់ចោទឈ្មោះ [redacted] ធីវ៉ាង កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ម៉ាត់សេន ឈ្មោះ [redacted] ជិន និង ដើមបណ្តឹងរដ្ឋប្បវេណី។

បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

**ឃ្មានឃើញ**ពាក្យបណ្តឹងទាស់លេខ០៩ចុះថ្ងៃទី២០.០២.២០១២របស់ឈ្មោះ [redacted] ម៉ាត់សេន មិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ០២«ក្រIIIយ»ចុះថ្ងៃទី០៤.០១.២០១២របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**ឃ្មានឃើញ**សាលដីកាព្រហ្មទណ្ឌស្តាពរលេខ៦៥«ក្រVIយ»ចុះថ្ងៃទី២០.៧.២០១២របស់សាលាឧទ្ធរណ៍ សំរេចសេចក្តីដូចតទៅ៖

១.ទទួលបណ្តឹងទាស់លេខ០៩ចុះថ្ងៃទី២០.០២.២០១២របស់ឈ្មោះ [redacted] ម៉ាត់សេន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់។

២.តំកល់សាលដីកាព្រហ្មទណ្ឌកំបាំងលេខ០២«ក្រIIIយ»ចុះថ្ងៃទី០៤.០១.២០១២របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែចំណុចទី២ត្រូវកែប្រែសំរេចជាថ្មីថា៖

ក/កែប្រែបទចោទលើឈ្មោះ [redacted] ម៉ាត់សេន ហៅ សាសាន់ ពីបទ ជួញដូរមនុស្សតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ ជួញដូរមនុស្ស និងធ្វើអាជីវកម្មលើមនុស្ស មកជាបទ ការនាំចេញដោយមិនស្របច្បាប់មានគោលដៅ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ ជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨វិញ និង តាមមាត្រា១០នៃក្រមព្រហ្មទណ្ឌ។

ខ/ចំណុចទណ្ឌកម្មពន្ធនាគារលើឈ្មោះ [redacted] ម៉ាត់សេន ហៅ សាហាន់ត្រូវបន្ថយមកត្រឹមចំនួន០៧ឆ្នាំ(ប្រាំពីរឆ្នាំ)វិញ។

គ/ចំណុចផ្សេងពីនេះរក្សាទុកជាបានការដដែល។

៣.សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី២០.៧.២០១២ ចំពោះមុខមេធាវី

ការពារសិទ្ធិជនជាប់ចោទ និង ប្រកាសកំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ.

**សំណុំរឿងទី២**

**សំណុំរឿងព្រហ្មទណ្ឌលេខ៣៧៣/២៩.៣.២០០៧របស់សាលាឧទ្ធរណ៍៖**

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ៩៣«ឃ»/២៨.៧.២០០៥សាលាដំបូងរាជធានីភ្នំពេញ សំរេចដូចតទៅ៖

.ផ្តន្ទាទោសឈ្មោះ

១[redacted]រ៉សេត ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរលក់ដូរ កើតនៅភូមិត្រពាំងឈូក ឃុំបឹង ស្រុកបារាយ ខេត្តកំពង់ចាម មានទីលំនៅសព្វថ្ងៃភូមិគីឡូម៉ែត្រ[redacted] ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]) ម្តាយឈ្មោះ[redacted] (រ) ប្រពន្ធឈ្មោះ[redacted]មានកូន៣នាក់ ទោសពីមុនគ្មាន ដាក់ពន្ធនាគារ កំណត់ចំនួន១០ឆ្នាំ (ដប់ឆ្នាំ) គិតចាប់តាំងពីថ្ងៃឃុំខ្លួនថ្ងៃទី០១.៣.២០០៥ ពីបទពង្រត់ មនុស្សយកទៅលក់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០១-៣-២០០៥ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ ជួញដូរមនុស្ស និងធ្វើអាជីវកម្មលើមនុស្ស។

២.[redacted]ម៉ាត់សេន ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរកងរាជអាវុធហត្ថ កើតនៅភូមិស្ទឹង ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅសព្វថ្ងៃភូមិ[redacted] ស្រុកពញាក្រែក ខេត្តកំពង់ចាម ឪពុកឈ្មោះ[redacted](ស) ម្តាយឈ្មោះ[redacted] (រ) ប្រពន្ធឈ្មោះ[redacted]មានកូន២នាក់ ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារកំណត់ចំនួន១២ឆ្នាំ (ដប់ពីរឆ្នាំ) គិតចាប់តាំងពីថ្ងៃឃុំខ្លួនថ្ងៃទី០៧.៣.២០០៥ ពីបទពង្រត់មនុស្សយកទៅលក់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០១-៣-២០០៥ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ ជួញដូរមនុស្ស និងធ្វើអាជីវកម្មលើមនុស្ស។

៣.ប្រគល់វត្ថុតាង មានកាបូបបត់ដាក់លុយរបស់ប្រុសចំនួន០២ ទូរស័ព្ទម៉ាកណូគាម៉ូដែល១១០០ ចំនួន០១គ្រឿង ទូរស័ព្ទម៉ាកណូគាម៉ូដែល៣៣៣០ ចាស់០១គ្រឿង និងប្រាក់ដុល្លាឲ្យម្ចាស់ដើមវិញ។

៤.សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិជនជាប់ចោទ ជនរងគ្រោះឈ្មោះ[redacted]ធីឡេហាវិនធៀង,ឈ្មោះ[redacted]ធីង៉ុកយៀម,ឈ្មោះ[redacted]ធីថាញហៀង កំបាំងមុខជនរងគ្រោះឈ្មោះ[redacted]ធីង៉ុកលី។បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០១.៨.២០០៥របស់ឈ្មោះ[redacted] ម៉ាត់សេន និង ឈ្មោះ[redacted]រ៉សេត មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៩៣«ឃ»/២៨.៧.២០០៥របស់សាលាដំបូងរាជធានីភ្នំពេញត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**បានឃើញ**សាលដីកាព្រហ្មទណ្ឌលេខ០៣«ង»ចុះថ្ងៃទី២៧.០១.២០១០របស់សាលាឧទ្ធរណ៍ សំរេចសេចក្តីដូចតទៅៈ

១.ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០១.៨.២០០៥របស់ឈ្មោះ [redacted] ម៉ាត់សេននិងឈ្មោះ [redacted] រ៉េសេក ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២.តំកល់សាលក្រមព្រហ្មទណ្ឌលេខ៩៣«ឃ»/២៨.៧.២០០៥សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ លើកលែងតែចំណុចទី១ និង ចំណុចទី២ ត្រូវកែប្រែថាៈ

ក/ផ្តន្ទាទោសឈ្មោះ [redacted] រ៉េសេក ភេទប្រុស អាយុ៣៥ឆ្នាំ ដាក់ពន្ធនាគារកំណត់១០ឆ្នាំ(ដប់ឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០៧.៣.២០០៥ ពីបទលក់ដូរមនុស្ស បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា១១នៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨វិញ។

ខ/ផ្តន្ទាទោសឈ្មោះ [redacted] ម៉ាត់សេន ហៅ ហាសាន់ ភេទប្រុស អាយុ៣៣ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន១២ឆ្នាំ (ដប់ពីរឆ្នាំ) បន្តពីសាលក្រមលេខ៩២«ឃ»/២៨.៧.២០០៥ ពីបទជួញដូរមនុស្ស បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា១១នៃច្បាប់ស្តីពីការបង្រ្កាបអំពើពង្រត់ ជួញដូរមនុស្ស និងធ្វើអាជីវកម្មលើផ្លូវភេទឆ្នាំ២០០៨។

.ចំណុចផ្សេងពីនេះនៃសាលក្រមរក្សាទុកជាបានការដដែល។

៣.សាលដីកានេះជំនុំជំរះនៅថ្ងៃទី១៩.០១.២០១០ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៧.០១.២០១០ចំពោះមុខមេធាវីការពារសិទ្ធិជនជាប់ចោទ កំបាំងមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី។បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

**បានឃើញ**ពាក្យបណ្តឹងទាស់លេខ១១ចុះថ្ងៃទី២១.០២.២០១២របស់ឈ្មោះ [redacted] ម៉ាត់សេន មិនសុខចិត្តនឹងសាលសាលដីកាព្រហ្មទណ្ឌលេខ០៣«ង»ចុះថ្ងៃទី២៧.០១.២០១០របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**បានឃើញ**សាលដីកាព្រហ្មទណ្ឌស្តាពរលេខ៦៦ក្រVIឃចុះថ្ងៃទី២០.៧.២០១២ របស់សាលាឧទ្ធរណ៍ សំរេចសេចក្តីដូចតទៅៈ

១.ទទួលបណ្តឹងទាស់ចុះថ្ងៃទី២១.០២.២០១២របស់ឈ្មោះ [redacted] ម៉ាត់សេនទុកជាត្រឹមត្រូវតាមទំរង់ច្បាប់។

២.តំកល់សាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ០៣«ង»ចុះថ្ងៃទី២៧.០១.២០១០ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែចំណុចទី២«ខ»ស្តីពីទណ្ឌកម្មលើឈ្មោះ [redacted] ម៉ាត់សេន ហៅ ហាហាន់ ត្រូវបន្ថយមកត្រឹម០៧ឆ្នាំ(ប្រាំពីរឆ្នាំ)វិញ។តាមមាត្រា៩៣,៩៤នៃក្រមព្រហ្មទណ្ឌ។

.ចំណុចផ្សេងពីនេះនៃសាលដីការក្សាទុកជាបានការដដែល។

៣.សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី២០.៧.២០១២ ចំពោះមុខមេធាវីការពារសិទ្ធិជនជាប់ចោទ និង ប្រកាសកំបាំងមុខជនជាប់ចោទតែចាត់ទុកជាចំពោះមុខ។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។
បានឃើញរបាយការណ៍របស់សាលាឧទ្ធរណ៍។
បានឃើញសេចក្តីសន្និដ្ឋានរបស់មហាអយ្យការសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ចៅក្រមអានរបាយការណ៍.

*ទណ្ឌិតឈ្មោះ* [redacted] *ម៉ាត់សេន ឆ្លើយថា៖* ខ្លួនមានអាយុ៤០ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរធ្វើចំការ កើតនៅភូមិស្ទឹង ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម មានទីលំនៅ [redacted] ក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន២នាក់ ទោសពីមុនគ្មាន។ ក្នុងឃុំ។ខ្លួនមានមេធាវី [redacted] សុភី ការពារឲ្យ។ខ្លួនជាប់ទោស០២រឿង ទណ្ឌកម្មពន្ធនាគារសរុបចំនួន១៨ឆ្នាំ។ខ្លួនជាប់ទោសបាន៩ឆ្នាំហើយ ជាប់នៅពន្ធនាគារខេត្តកំពង់ចាម ។ ម្តាយខ្លួនចាស់ណាស់ហើយ សុំបានទៅជួយមើលថែទាំម្តាយ។ខ្លួនមិនមានជាប់ទោសអ្វីទៀតទេ។នៅក្នុងពន្ធនាគារខ្លួនកែខ្លួនបានល្អ មិនដែលធ្វើឲ្យមានការលំបាកបង្ករឿងហេតុអ្វីទេ ហើយពេលចេញក្រៅខ្លួនសន្យានឹងកែខ្លួនឲ្យបានល្អ មិនឲ្យមានលើកទី២ទៀតទេ។សំណូមពរសុំស្រូបទោសត្រឹម៩ឆ្នាំ ។

*តំណាងមហាអយ្យការសន្និដ្ឋានថា៖*ឆ្លងតាមការសួរដេញដោល ទណ្ឌិតឈ្មោះ [redacted] ម៉ាត់សេន ត្រូវបានផ្តន្ទាទោសពន្ធនាគារ មានសាលដីកា០២៖ មានទោសចំនួន០៧ឆ្នាំ (ប្រាំពីរឆ្នាំ)តាមសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ៦៥ក្រVIយេចុះថ្ងៃទី២០.៧.២០១២ ២០១២របស់សាលាឧទ្ធរណ៍ និង មានទោសចំនួន០៧ឆ្នាំ(ប្រាំពីរឆ្នាំ)តាមសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ៦៦ក្រVIយេចុះថ្ងៃទី២០.៧.២០១២របស់សាលាឧទ្ធរណ៍។ទណ្ឌិតរូបនេះក្រោយពីបានទទួលទោសក្នុងពន្ធនាគារកន្លងមក មានការកែប្រែអត្តចរិតបានល្អ ហើយពុំដែលបង្កការលំបាកដល់មន្ត្រីពន្ធនាគារម្តងណាឡើយ ទណ្ឌកម្មពន្ធនាគារសរុបចំនួន ១៨ឆ្នាំ ជាប់ទោសបាន៩ឆ្នាំហើយ សុំក្រុមប្រឹក្សាពិចារណាអំពីការសុំស្រូបទោសតាមមាត្រា១៣៨នៃក្រមព្រហ្មទណ្ឌ ។

*មេធាវី* [redacted] *សុភី សន្និដ្ឋានថា៖*ខ្លួនជាមេធាវីការពារឲ្យឈ្មោះ [redacted] ម៉ាត់សេន។កូនក្តីខ្លួនជាប់ទោស០២រឿង ទណ្ឌកម្មពន្ធនាគារសរុបចំនួន១៨ឆ្នាំ។កូនក្តីខ្លួនជាប់ទោសបាន៩ឆ្នាំហើយ ជាប់នៅពន្ធនាគារខេត្តកំពង់ចាម ។ម្តាយកូនក្តីខ្លួនចាស់ជរាណាស់ហើយ សុំទៅជួយមើលថែរទាំម្តាយ។កូនក្តីខ្លួនមិនមានជាប់ទោសអ្វីទៀតទេ។នៅក្នុងពន្ធនាគារ កូនក្តីខ្លួនកែខ្លួនបានល្អ មិនដែលធ្វើឲ្យមានការលំបាកបង្ករឿងហេតុអ្វីទេ ហើយពេលចេញក្រៅ សន្យានឹងកែខ្លួនឲ្យបានល្អ មិនឲ្យមានលើកទី២ទៀតទេ។សំណូមពរសុំសំរេចស្រូបទោសត្រឹម៩ឆ្នាំដល់កូនក្តីខ្លួន ។

ក្រោយពីបានស្តាប់ចំលើយទណ្ឌិត.

[redacted]

ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន.

ក្រោយពីបានស្តាប់មេធាវីសន្និដ្ឋាន.

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

**សភាព្រហ្មទណ្ឌ យល់ឃើញថា**

១-បណ្តឹងសុំស្រូបទោសចុះថ្ងៃទី១៧-៥-២០១៣របស់ទណ្ឌិតឈ្មោះ[redacted] ម៉ាត់សេន ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ តាមមាត្រា៥០១នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.ទណ្ឌិតឈ្មោះ[redacted] ម៉ាត់សេន ហៅ ហាសាន់ ត្រូវបានផ្តន្ទាទោសពន្ធនាគារៈ

.ចំនួន០៧ឆ្នាំ(ប្រាំពីរឆ្នាំ)តាមសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ៦៥ក្រVIយចុះថ្ងៃទី ២០.៧.២០១២របស់សាលាឧទ្ធរណ៍។

.ចំនួន០៧ឆ្នាំ(ប្រាំពីរឆ្នាំ)តាមសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ៦៦ក្រVIយចុះថ្ងៃទី ២០.៧.២០១២របស់សាលាឧទ្ធរណ៍។

៣.ទណ្ឌិតរូបនេះ ក្រោយពីបានទទួលទោសក្នុងពន្ធនាគារកន្លងមក ទណ្ឌិតរូបនេះ មានការកែប្រែអត្តចរិតច្រើន ហើយពុំដែលបង្កការលំបាកដល់មន្ត្រីពន្ធនាគារម្តងណាឡើយ គប្បីក្រុមប្រឹក្សាពិចារណាអំពីការសុំស្រូបទោស។

ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យសុំស្រូបទោសចុះថ្ងៃទី១៧-៥-២០១៣របស់ទណ្ឌិតឈ្មោះ[redacted] ម៉ាត់សេន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២.ឲ្យស្រូបទោសពន្ធនាគារដែលប្រកាសលើឈ្មោះ[redacted] ម៉ាត់សេន ចំនួន០៧ឆ្នាំ (ប្រាំពីរឆ្នាំ)តាមសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ៦៥ក្រVIយចុះថ្ងៃទី២០.៧.២០១២មួយផ្អែកទៅក្នុងសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ៦៦ក្រVIយចុះថ្ងៃទី២០.៧.២០១២មានទោសចំនួន០៧ឆ្នាំ(ប្រាំពីរឆ្នាំ)របស់សាលាឧទ្ធរណ៍ មានទោសសរុបចំនួន១៤ឆ្នាំ គឺទោសត្រូវអនុវត្ត សរុបចំនួន១០ឆ្នាំ(ដប់ឆ្នាំ)។

៣.សាលដីកានេះប្រកាសជាសាធារណៈថ្ងៃទី០៦.០២.២០១៤ចំពោះមុខទណ្ឌិត។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកំលាំងប្រដាប់អាវុធគ្រប់ដំណែងជួយសហការអនុវត្តសាលដីកានេះឲ្យបានសំរេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

**ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

ហត្ថលេខា[redacted].ហត្ថលេខា[redacted] ហត្ថលេខា [redacted]

បានចតចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍,ថ្ងៃទី០៤ ខែ ៣ ឆ្នាំ២០១៤

**ក្រឡាបញ្ជី**

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍**

[redacted] [redacted]



០៧